COPY

# កិច្ចព្រមព្រៀង

## រវាង

## ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា

## និង

## ក្រសួងមហាផ្ទៃនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

## ស្តីពី

## កិច្ចសហប្រតិបត្តិការ ការទប់ស្កាត់ និង ប្រឆាំងបទល្មើស

ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និង ក្រសួងមហាផ្ទៃនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលខាងក្រោមនេះហៅថា " ភាគីទាំងពីរ " ។

-ដោយផ្តើមចេញពីគោលបំណងបង្កើនទំនាក់ទំនង សហប្រតិបត្តិការ សាមគ្គីភាព មិត្តភាព និង កសាងនូវទំនាក់ទំនងជិតខាងល្អ

-ផ្អែកលើមូលដ្ឋាន គោរព ឯករាជ្យ អធិបតេយ្យភាព បូរណភាពដែនដី និង សន្តិសុខរបស់ប្រទេសនិមួយៗ ស្មើភាព មានផលប្រយោជន៍ទៅវិញទៅមក មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្នា គោរពច្បាប់អន្តរជាតិ និង ច្បាប់របស់ប្រទេសនិមួយៗ

ភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចខាងក្រោម ៖

### <u>ប្រការ មួយ</u>

ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ភាគីកិច្ចទាំងពីរឯកភាពធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីទប់ស្កាត់បង្ការ តស៊ូ និង ប្រឆាំងរាល់សកម្មភាពខុសច្បាប់ និង បទល្មើសដូចខាងក្រោមនេះ ៖

១-ការលក់ដូរ និង ដឹកជញ្ជូនខុសច្បាប់នូវអាវុធយុទ្ធភ័ណ្ឌព្រមទាំងអាវុធគីមី គ្រាប់រំសេវ ជាតិផ្ទុះ សារធាតុមានកាំរស្មីគ្រប់ប្រភេទ ។

២-ការធ្វើជំនួញ និង ដឹកជញ្ជូន ឆ្លងកាត់ខុសច្បាប់នៃគ្រឿងញៀន និង សារធាតុញៀនដែលធ្វើអោយខូចសរសៃប្រសាទ ។

៣-សកម្មភាពភេរវកម្ម និង ការប្រព្រឹត្តបទល្មើសដោយមានរៀបចំជាអង្គការចាត់តាំង និង រាល់សកម្មភាពផ្សេងៗទៀត ដែលបង្កអោយមានអសន្តិសុខ និង ពាត់សណ្តាប់ធ្នាប់សង្គមរបស់ប្រទេសទាំងពីរ ។

៤-ការរត់ពន្ធឆ្លងកាត់ព្រំដែន ។

៥-ការផលិត និង ចរាចរប្រើបិយវត្ថុក្លែងក្លាយ ឬ ប្រើប្រាស់លិខិតស្នាមក្លែងក្លាយ ។

៦-ការលក់ដូរមនុស្សពេញវ័យ និង កុមារ ។

៧-ការឆ្លងកាត់ព្រំដែនដោយខុសច្បាប់ ឬ សកម្មភាពបង្កអោយបាត់សណ្តាប់ធ្នាប់ អសន្តិសុខព្រំដែន ។

## ប្រការ ពីរ

ដើម្បីអនុវត្តប្រការមួយនៃកិច្ចព្រមព្រៀងនេះ ភាគីទាំងពីរចាប់ផ្តើមធ្វើសហប្រតិបត្តិការតាមរូបភាពដូចខាងក្រោម ៖

១-ផ្លាស់ប្តូរទាន់ពេលវេលានូវពតិមាន ដំណឹង ឯកសារដែលភាគីទាំងពីរចាប់អារម្មណ៍ ព្រមទាំងមានវិធានការការពារយ៉ាងសម្ងាត់ នូវរាល់ពតិមាន ដំណឹង និង ឯកសារទាំងនោះ ។ រាល់ពតិមាន និង ដំណឹង ឯកសារទាំងនោះមិនត្រូវបានផ្តល់អោយភាគីទីបីដាច់ខាត ។

២-ក្នុងករណីចាំបាច់ តាមសំណូមរបស់ភាគីម្ខាងៗ ភាគីទាំងពីរនឹងជួបពិភាក្សាជាមួយគ្នា ដើម្បីដាក់ចេញនូវរាល់វិធានការសំដៅទប់ស្កាត់ និង ធ្វើការតស៊ូអោយមានប្រសិទ្ធភាពចំពោះការប្រព្រឹត្តបទល្មើស និង ដោះស្រាយភាពស្មុគស្មាញនៃបទល្មើសដែលកើតមានឡើងទាំងនោះ ។

៣-សហការ និង ស៊ើបអង្កេត ស្រាវជ្រាវជាមួយគ្នា ដើម្បីចាប់ និង ឃាត់ខ្លួនទុក នូវរាល់សមាសភាពដែលប្រព្រឹត្តបទល្មើសនៅប្រទេសនៃភាគីកិច្ចព្រមព្រៀងមួយ ហើយរត់គេចខ្លួនទៅនៅប្រទេសភាគីកិច្ចព្រមព្រៀងមួយទៀត ព្រមទាំងជូនដំណឹង និង ប្រគល់ជូនគ្នាទៅវិញទៅមកនូវជនល្មើស សាក្សី និង ភស្តុតាងផ្សេងៗ ។

៤-ភាគីទាំងពីរឯកភាពអនុវត្តនូវរាល់វិធានការ ដើម្បីកុំអោយរាល់សមាសភាពអាក្រក់ប្រើប្រាស់ ដែនដី ដែនទឹករបស់ប្រទេសនិមួយៗដើម្បីធ្វើសកម្មភាព ឬ បង្កើតអង្គការចាត់តាំងសំដៅធ្វើសកម្មភាពបង្កអស្ថេរភាព អសន្តិសុខខាងនយោបាយ និង បាត់សណ្តាប់ធ្នាប់សង្គមរបស់ប្រទេសមួយទៀត ។

## ប្រការ បី

ដើម្បីធានាសន្តិសុខខាងនយោបាយ និង សណ្តាប់ធ្នាប់សង្គមនៅតាមតំបន់ជនបទនៃព្រំដែនរវាងប្រទេសទាំងពីរ ៖

១-ភាគីទាំងពីរមានភារកិច្ចឃោសនា អប់រំប្រជាជននៅតំបន់ព្រំដែន អោយគោរពស្មារតីសាមគ្គីភាព ច្បាប់អន្តរជាតិ ច្បាប់ផ្ទៃក្នុង និង បទបញ្ញត្តិព្រំដែន ដែលបានចុះហត្ថលេខាដោយរដ្ឋាភិបាល នៃប្រទេសទាំងពីរ ដើម្បីរក្សាអោយបានរឹងមាំ នូវ សន្តិភាព មិត្តភាព ស្ថេរភាព សន្តិសុខនយោបាយ និង សណ្តាប់ធ្នាប់សង្គមនៅតាមតំបន់ព្រំដែន ។

២-សហការរៀបចំនូវរាល់វិធានការបង្ការ ទប់ស្កាត់អំពើល្មើសកិច្ចព្រមព្រៀងព្រំដែន និង អំពើឧក្រិដ្ឋ

ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់ និង ស្ថេរភាពនៅតាមតំបន់ព្រំដែន ធានាសុវត្ថិភាពជូនប្រជាពលរដ្ឋនៃប្រទេសរៀងខ្លួនដែលចេញ ចូល រស់នៅ សិក្សា បំពេញបេសកកម្ម ស្វះស្វែងរកសុខទុក្ខញាតិសន្តាន និង ធានាសុវត្ថិភាពក្នុងការដឹកជញ្ជូន ឆ្លងកាត់រវាងប្រទេសទាំងពីរតាមការព្រមព្រៀងរវាងរដ្ឋាភិបាលទាំងពីរ ។

៣-ចំពោះពលរដ្ឋដែលរស់នៅតាមតំបន់ព្រំដែន ដែលបានប្រព្រឹត្តល្មើសនឹងកិច្ចព្រមព្រៀងព្រំដែន ភាគីទាំងពីរត្រូវជូនដំណឹងគ្នាទៅវិញទៅមកអោយឆាប់រហ័ស ដើម្បីសហការរួមគ្នាដោះស្រាយ ។

## ប្រការ បួន

ភាគីទាំងពីរនឹងចាត់បញ្ជូនគណៈប្រតិភូ ទៅបំពេញទស្សនកិច្ចទៅវិញទៅមក ដើម្បីផ្លាស់ប្តូរបទពិសោធន៍អំពីការងារនគរបាល ចរចា និង ពិភាក្សាវិធានការអនុវត្តកិច្ចព្រមព្រៀង ពង្រីកទំនាក់ទំនង សហប្រតិបត្តិការមិត្តភាពរវាងវិស័យនគរបាលនៃប្រទេសទាំងពីរ ទន្ទឹមនឹងនោះកសាង និង បង្កើនទំនាក់ទំនងផ្ទាល់រវាងកងកម្លាំងនគរបាលជាតិនៅតាមតំបន់ព្រំដែន ។

## ប្រការ ប្រាំ

តាមសំណូមពររបស់ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃនៃសាធារណរដ្ឋសង្គមនិយមវៀតណាម តាមលទ្ធភាពរបស់ខ្លួន ឯកភាពជួយបណ្តុះបណ្តាលបំប៉នមុខជំនាញដល់នគរបាលជាតិកម្ពុជា ស្របតាមការជាក់ស្តែងដែលភាគីទាំងពីរឯកភាព ។

## ប្រការ ប្រាំមួយ

រាល់ចំណាយក្នុងការធ្វើដំណើរទៅមករបស់គណៈប្រតិភូ ត្រូវបានអនុវត្តតាមកិច្ចព្រមព្រៀងនេះ ដោយភាគីបញ្ជូនជាអ្នកទទួលខុសត្រូវ ។ ចំណាយក្នុងការហូបចុក ស្នាក់នៅ និង មធ្យោបាយធ្វើដំណើរក្នុងរយៈពេលស្នាក់នៅ ប្រទេសម្ចាស់ផ្ទះជាអ្នកទទួលខុសត្រូវ ។

## ប្រការ ប្រាំពីរ

ក្នុងពេលអនុវត្តកិច្ចព្រមព្រៀងនេះ បើមានបញ្ហាកើតឡើង ភាគីទាំងពីរត្រូវសហការរួមគ្នាដោះស្រាយដោយឈរលើ ស្មារតីយោគយល់ និង សាមគ្គីភាព មិត្តភាព ។ ប្រសិនបើឆ្លងកាត់ការពិភាក្សាហើយ ភាគីទាំងពីរពុំអាចរក ឃើញនូវដំណោះស្រាយបាន ភាគីនីមួយៗត្រូវស្នើសុំទៅរដ្ឋាភិបាលរបស់ខ្លួន ដើម្បីធ្វើការដោះស្រាយក្នុងកំរិតរដ្ឋាភិបាល ។

## <u>ប្រការ ប្រាំបី</u>

កិច្ចព្រមព្រៀងនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា និង មានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ បើភាគីណាមួយក្នុងភាគីទាំងពីរ ចង់បញ្ឈប់កិច្ចព្រមព្រៀងនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអោយភាគីម្ខាងទៀតមុនបីខែ ។ បើភាគីទាំងពីរមិនបានលើកសំណូមពរបញ្ឈប់ កិច្ចព្រមព្រៀងនេះនឹងមានប្រសិទ្ធិភាពបីឆ្នាំបន្តទៀតជាស្វ័យប្រវត្តិ ។

កិច្ចព្រមព្រៀងនេះធ្វើនៅរាជធានីភ្នំពេញនាថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៩៧ ដែលធ្វើជាពីរច្បាប់ជាភាសាខ្មែរ និង ភាសាវៀតណាម ហើយមានតម្លៃដូចគ្នា ។

| | |
|---|---|
| **សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ<br>នៃព្រះរាជាណាចក្រកម្ពុជា** | **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ<br>នៃសាធារណរដ្ឋសង្គមនិយមវៀតណាម** |
| ស ខេង      យូ ហុកគ្រី | ឡេ មិញហឿង |